# សំណូមពរចំពោះលោកអ្នកដែលនៅក្រុងតូក្យូ ទាក់ទងនឹងវីរុសកូវីដ19

○ បច្ចុប្បន្ននេះអ្នកឆ្លងជំងឺកូវីដ19 មានចំនួនច្រើនខ្លាំង។ បើកើនឡើងទៀត នោះគឺគ្រោះថ្នាក់។ គឺគ្រោះថ្នាក់ណាស់។

○ ទីក្រុងតូក្យូបានចេញសេចក្តីប្រកាសអាសន្នរួចហើយ។ បច្ចុប្បន្ននេះអ្វីដែលសំខាន់គឺត្រូវនៅផ្ទះ កុំចេញទៅក្រៅតាមដែលអាចធ្វើទៅបាន។ ហើយជៀសវាងជួប ឬនិយាយជាមួយមនុស្ស។

○ សេចក្តីប្រកាសអាសន្នគឺជាសំណូមពរចំពោះលោកអ្នក សុំឲ្យប្តូររបៀបរស់នៅ។

**ពីពេលណាដល់ពេលណា**

ពីថ្ងៃទី1 ខែមិថុនា(ថ្ងៃអង្គារ) ម៉ោង0 ដល់ ថ្ងៃទី20 ខែមិថុនា(ថ្ងៃអាទិត្យ) ម៉ោង12 យប់

## សំណូមពរ

**អ្នករស់នៅក្រុងតូក្យូ**

<u>សូមនៅផ្ទះ</u>

○ សូមនៅផ្ទះតាមដែលអាចធ្វើបាន។ សូមកុំចេញទៅក្រៅតាមដែលអាចធ្វើបាន។

○ សូមនៅផ្ទះនៅពេលយប់ និងថ្ងៃសៅរ៍ ថ្ងៃអាទិត្យ។

○ សូមកុំចូលក្នុងក្រុងតូក្យូ និងកុំចេញពីក្រុងតូក្យូ។

**អ្នកបើកហាង**

<u>សំណូមពរទាក់ទងនឹងការផ្អាកបើកហាង ការកាត់បន្ថយម៉ោងបើក កម្មវិធី។ល។</u>

*សូមមើលនៅទំព័របន្ទាប់។

# កន្លែងអាជីវកម្មសំណូមពរ

## ● ខុសគ្នាទៅតាមទំហំនៃកន្លែងអាជីវកម្ម

| | ឧទាហរណ៍នៃទីកន្លែង | ប្រការសំណូមពរ |
|---|---|---|
| កន្លែង -ហាង | ផ្សារទំនើប មជ្ឈមណ្ឌលទិញទំនិញ។ល។ (ក្រៅពីកន្លែងលក់ចាំបាច់សម្រាប់ការរស់នៅ) | 【កន្លែងធំជាង 1,000㎡】 (ក្រៅពីកន្លែងលក់ចាំបាច់សម្រាប់ការរស់នៅ)<br>● ថ្ងៃធម្មតា៖ ម៉ោងអាចបើកហាងបាន៖ ពីម៉ោង5 ដល់ ម៉ោង20 សូមកាត់បន្ថយចំនួនមនុស្សចូលក្នុងហាង<br>● ថ្ងៃសៅរ៍ ថ្ងៃអាទិត្យ៖ សូមឈប់សម្រាក<br>【កន្លែងតូចជាង1,000㎡】 (ក្រៅពីកន្លែងលក់ចាំបាច់សម្រាប់ការរស់នៅ)<br>●ម៉ោងអាចបើកហាងបាន៖ ពីម៉ោង5 ដល់ ម៉ោង20 សូមកាត់បន្ថយចំនួនមនុស្សចូលក្នុងហាងអោយបានច្រើនបំផុត |
| | ហាងជាំឈើងកុ កន្លែងលេងហ្គេម។ល។ | |
| | កន្លែងងូតទឹកសាធារណៈដែលមានបន្ទប់ ដោយឡែក ហាងមើលវីដេអូក្នុងបន្ទប់ដោយឡែក។ល។ | |
| | កន្លែងងូតទឹកប្រណិត ហាងសាឡន។ល។ | |
| កន្លែង -កម្មវិធី | សារមន្ទីរ វិចិត្រសាលសិល្បៈ សួនសត្វ។ល។ | ● សូមកម្រិតចំនួនភ្ញៀវឲ្យនៅក្រោម 5,000 នាក់ សូមឲ្យភ្ញៀវចូលត្រឹម50% នៃចំនួនភ្ញៀវដែលអាចចូលបាន<br>● ម៉ោងអាចបើកហាងបាន៖<br>○ នៅពេលមានកម្មវិធី ត្រឹមម៉ោង21<br>○ នៅពេលគ្មានកម្មវិធី<br>កន្លែងធំជាង1,000㎡ ៖ ត្រឹមម៉ោង20<br>កន្លែងតូចជាង1,000㎡ ៖ ព្យាយាមបិទត្រឹមម៉ោង20<br>● សូមកាត់បន្ថយចំនួនមនុស្សចូលក្នុងហាង |
| | ទីលានកីឡាបេស្បល អាគារលេងកីឡា ក្លឹបហាត់ប្រាណ។ល។ | |
| | រោងភាពយន្ត មហោស្រព កន្លែងសំដែង។ល។ | |
| | សួនកំសាន្ត theme park សួនកំសាន្ត | |
| | កន្លែងជួបជុំ សាលជួបជុំសាធារណៈ។ល។ | |
| | សាលពិព័រណ៌ សាលវប្បធម៌។ល។ | |
| | សណ្ឋាគារ ផ្ទះសំណាក់ (តែកន្លែងជួបជុំប៉ុណ្ណោះ) | |

# កន្លែងអាជីវកម្មសំណូមពរ （ភោជនីយដ្ឋាន ហាងកាហ្វេជាដើម）

## កន្លែងសំណូមពរឲ្យផ្អាកបើក ／ កន្លែងសំណូមពរឲ្យកាត់បន្ថយចំនួនម៉ោងបើក

| កន្លែង | ឧទាហរណ៍-កន្លែង | ប្រភេទសំណូមពរ |
|---|---|---|
| ហាងហូបចុក/កន្លែងកំសាន្ត<br>ប្រសិនបើមាន១ក្នុងចំណោម ①～③<br>①បំរើគ្រឿងស្រវឹង<br>②អាចយកគ្រឿងស្រវឹងចូលបាន<br>③មានខារ៉ាអូខេ | 【ហាងហូបចុក】<br>ភោជនីយដ្ឋាន （រួមទាំងភោជនីយដ្ឋានអ៊ីហ្សាកាយ៉ា） ហាងកាហ្វេ។ល។<br>（ក្រៅពីសេវាកម្មដឹកជញ្ជូនដល់ផ្ទះ និងខ្ចប់）<br><br>【កន្លែងកំសាន្ត】<br>ក្លឹបរាត្រី បារ។ល។ | សូមផ្អាកបើក |
| ហាងហូបចុក/កន្លែងកំសាន្ត （គ្មានទាំងអស់）<br>①មិនបំរើគ្រឿងស្រវឹង<br>②ភ្ញៀវមិនអាចយកគ្រឿងស្រវឹងចូលបាន<br>③គ្មានខារ៉ាអូខេ | | ● ម៉ោងអាចបើកហាងបាន៖ ត្រឹមម៉ោង20<br>● សូមកាត់បន្ថយចំនួនមនុស្សចូលក្នុងហាង<br>● សូមគោរពតាមគោលការណ៍ណែនាំនៃប្រភេទអាជីវកម្មនីមួយៗ |
| កន្លែងជួបជុំ។ល។ | កន្លែងពិធីអាពាហ៍ពិពាហ៍ | ● សូមកុំបំរើគ្រឿងស្រវឹង<br>● ភ្ញៀវក៏មិនអាចយកគ្រឿងស្រវឹងចូលបានដែរ<br>● សូមកុំប្រើប្រាស់ខារ៉ាអូខេ<br>● ម៉ោងអាចបើកកន្លែងបាន៖ ត្រឹមម៉ោង20<br>● សូមរៀបចំធ្វើ "ត្រឹម1.5 ម៉ោង" "ត្រឹម50នាក់ និងត្រឹម50% នៃចំនួនមនុស្សអាចចូលបាន" |